ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៨ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការសិក្សា និងរៀបចំសាងសង់អគារទីស្តីការនាយករដ្ឋមន្ត្រី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងស្មារតីអង្គប្រជុំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៩

### សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការសិក្សា និងរៀបចំសាងសង់អគារទីស្តីការនាយករដ្ឋមន្ត្រី ដូចមានសមាសភាពខាងក្រោម :

១- សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧត្តម **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ប្រធាន

២- ឯកឧត្តម **អ៊ឹម ឈុនលឹម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៣- ឯកឧត្តម **ប្រាក់ សុខុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៤- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម **កែប ជុំតិមា** អភិបាលរាជធានីភ្នំពេញ អនុប្រធាន

៦- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

៧- ឯកឧត្តម **ទី សុខុន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ សមាជិក

៨- ឯកឧត្តម **លោ សុធន** អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩- ឯកឧត្តម **រ៉េត បូរី** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី សមាជិក

១០- ឯកឧត្តម **អ៊ុងផេង ពុទ្ធវិសាល** ជំនួយការសម្តេចចៅហ្វាវាំង និងប្រធាននាយកដ្ឋានសំណង់ ក្រសួង ព្រះបរមរាជវាំង សមាជិក

១១- ឧត្តមសេនីយត្រី **ឃឹម សុខ** នាយករងនាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ សមាជិក

១២- លោក **នាយ ឫទ្ធីសែន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ សមាជិក

១៣- លោក **យស់ វេទាយណារ៉ាទី** អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ សមាជិក

១៤- លោក **សារិន វណ្ណា** អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ សមាជិក

១៥- លោក **យស់ វណ្ណា** ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌចំការមន សមាជិក

១៦- លោក **ប្រាក់ សោភ័ណ** សមាជិកក្រុមលេខាសម្តេចតេជោ នាយករដ្ឋមន្ត្រី សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចសហការរៀបចំ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន :

ក-ក្រុមហ៊ុន លី ឈួង សំណង់ និង អាហារណ៍ នីហារណ៍ ( Ly Chhuong Construction & Import , Export Co.,Ltd.) លើការងារសិក្សាគំរោងប្លង់ គម្លើងប្លង់ស្ថាបត្យកម្ម និងការងារសាងសង់អគារដែលមានសមាសភាព :

១-លោក **លី ឈួង** នាយកក្រុមហ៊ុន

២-លោក **គង់ វណ្ណារិទ្ធ** បណ្ឌិតវិទ្យាសាស្ត្របច្ចេកទេស

៣-លោក **ប៉ែន តារាវិន** ស្ថាបត្យករ

ខ-ក្រុមហ៊ុន VISPAN Co.,Ltd. លើការងារសិក្សា បំពាក់គ្រឿងសំភារៈ និងតុបតែងខាងក្នុងអគារដែលមានសមាសភាព ៖

១-លោក **ខៀវ វិណ្ណ** ស្ថាបត្យករ DPLG

២-លោក **អ៊ុនផេង ពុធវិសាល** ស្ថាបត្យករ

៣-លោកស្រី **ផង់ បញ្ញា** ស្ថាបត្យករ

៤-លោក **ព្រំ ពិសុទ្ធ** ស្ថាបត្យករ

ប្រការ ៣ ៖ គណៈកម្មការនេះមានតួនាទី និងភារកិច្ចទទួលខុសត្រូវ ៖

- រៀបចំប្លង់ទីតាំងរួម ប្លង់ស្ថាបត្យកម្ម ប្លង់រចនាសម្ព័ន្ធ ប្លង់សាងសង់ ប្លង់បំពាក់គ្រឿងសម្ភារៈតុបតែង និងថវិកាចំណាយលើការសាងសង់ ជូននាយករដ្ឋមន្ត្រី ពិនិត្យ និងសំរេច។
- រៀបចំផែនការសាងសង់ និងតាមដានត្រួតពិនិត្យការអនុវត្ត ព្រមទាំងសម្របសម្រួលការងារជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងគំរោង និងរាយការណ៍ជូន និងសុំសេចក្តីសំរេចពីនាយករដ្ឋមន្ត្រី ដើម្បីឱ្យការសាងសង់នេះសំរេចបានទាន់ ពេលវេលានៃកិច្ចសន្យាសាងសង់ ។
- អនុវត្តភារកិច្ចដទៃទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ។

ប្រការ ៤ ៖ គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណកម្មការមួយចំនួន តាមតម្រូវការចាំបាច់ ។

ប្រការ ៥ ៖ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានគណៈកម្មការ ។

ប្រការ ៦ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកគណៈកម្មការដូចមានចែងក្នុងប្រការ ១ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ-កាលប្បវត្តិ*